# រឿង ចចក និង ទុង



# រឿង ចចក និងទុង

និពន្ធនិងរៀបរៀងដកស្រង់ពី សៀវភៅគតិលោក ភាគ៥

គូររូបដោយ លោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្មាគ្រចិត្ត(SVA)

បោះពុម្ពឆ្នាំ២០០១

# បុព្វកថា

******

ប្រភេទសៀវភៅនិទានរឿងព្រេងខ្មែរដោយរូបភាពសំរាប់កុមារនេះ បានរៀបរៀងឡើងក្នុងគោលបំណងៈ

- ធ្វើឱ្យកុមារមានសេចក្ដីសប្បាយរីករាយ
- ជួយដល់ការលូតលាស់ផ្នែកស្មារតី និងអប់រំបញ្ញារបស់កុមារ
- ឱ្យកុមារស្គាល់វប្បធម៌របស់ខ្មែរ
- ជួយដល់ឪពុកម្ដាយ ឬលោកគ្រូ អ្នកគ្រូ  ក្នុងការនិទានរឿងផ្សេង ៗ សំរាប់កុមារ

យើងខ្ញុំរង់ចាំទទួលនូវការផ្ដល់មតិកែលំអ ពីមិត្តអ្នកអានទាំងអស់ដោយសេចក្ដីសោមនស្សរីករាយជាទីបំផុត ។

សូមអរគុណ !

ចចកដែលរស់នៅឯកោតែឯងនៅក្នុងផ្ទះមួយ បានដើរតិបតុបៗ ចុះឡើងៗ និងរអ៊ូផងថា : «អផ្សុកណាស់ ! អផ្សុកណាស់ ! ខ្ញុំចង់បានមិត្រសម្លាញ់ !» ។ ចចកបានចុះពីកំពូលភ្នំឆ្ពោះទៅភូមិឯជើងភ្នំ ។







ចចកបានមកដល់ផ្ទះទុង   ជួនពេលដែលទុងបំរុង

ចេញទៅរកចំណី ។





ចចកបាននិយាយទៅកាន់ទុងថា៖ « សូមបងយកខ្ញុំជាមិត្រផង » ។ ទុងមានការភ្ញាក់ផ្អើលបន្តិច តែទុងដែលរស់នៅឯកោម្នាក់ឯងដែរនោះ ក៏សម្រេចចិត្តយកចចកជាមិត្រយ៉ាងរីករាយ ។





ថ្ងៃមួយចចកនិយាយបបួលទុងថា៖ «សម្លាញ់អើយ ! ថ្ងៃនេះ ខ្ញុំសុំអញ្ជើញឯងទៅជប់លៀងនៅឯផ្ទះខ្ញុំបានម្តង» ។





ចចកបានធ្វើម្ហូបអាហារដាក់នៅក្នុងថាសមានផ្ទៃរាបស្មើ ដូចដែលខ្លួនធ្លាប់បរិភោគ ដោយមិនបានគិតពីការទម្លាប់របស់ទុង ។ ទុងបានធ្វើដំណើរមកដល់ផ្ទះចចកដោយក្ដីរីករាយបំផុត ។





ទុងបានប្រឹងចឹកអាហារនៅក្នុងថាស តែដោយសារ ចំពុះវែងពេក ក៏មិនអាចបរិភោគអាហារបានឡើយ ។ ចចកបរិភោគពេញពោះឆ្អែតតែម្នាក់ឯង។ ឯទុងនៅពោះទទេ ក៏ត្រឡប់ទៅផ្ទះវិញក្ងួរពោះគ្រួកៗ! គ្រួកៗ! ។



បីថ្ងៃបន្ទាប់មកទុងក៏បានអញ្ជើញចចកមកជប់លៀង
នៅផ្ទះរបស់ខ្លួនម្ដងវិញ ។



ទុងបានយកថូដែលមានមាត់ តូចមកដាក់ចំណីអាហារ
នៅក្នុងនោះ រួចទុងក៏អញ្ជើញ ចចកដោយរាក់ទាក់៖
សូមសម្លាញ់ពីសាឱ្យឆ្អែតចុះ» ។
អរគុណ ! អរគុណ!» ចចកតបយ៉ាងរីករាយ ។ ទុង
ដែលមានចំពុះវែងបានបរិភោគចំណីអាហារយ៉ាងស្រួល
រហូតឆ្អែតស្កប់ស្កល់





ចំណែកឯចចកមាត់ធំល្ងូកមិនចុះទៅក្នុងថូ បរិភោគ ក៏មិនកើត ចេះតែអង្គុយស្មៀម ពោះក៏ឃ្លានក្លូរគ្រូកៗ ។ ចប់ពិធីជប់លៀង ចចកលាទុងវិលទៅផ្ទះវិញជាមួយនឹងការអៀនខ្មាសយ៉ាងខ្លាំង ៕

៙ចប់៙



545000

